ព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋាន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# ស្ដីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែសីហា និងទិសដៅការងារខែកញ្ញា ឆ្នាំ២០១៣

នៅក្នុងខែសីហានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបំពេញការងារយ៉ាងសកម្ម លើការដ្ឋានជាច្រើនដោយផ្សារភ្ជាប់បទដ្ឋាន ការងាររដ្ឋបាល បច្ចេកទេស នីតិវិធី និងហិរញ្ញវត្ថុ ជាពិសេសការផ្ដល់សេវាជូនអគ្គលេខាធិការដ្ឋាន និងព្រឹទ្ធសភា មានលក្ខណៈប្រក្រតី មានស្មារតីសហការគ្នាបានល្អក្នុងការងារ និងខិតខំពង្រឹងពង្រីកភាពសុខដុមផ្ទៃក្នុង បង្កើតសេវាថ្មីៗ ការកសាងគោលនយោបាយនានា ពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការជាតិ អន្តរជាតិ និងបំពេញការងារសំខាន់ៗមួយចំនួនទៀតដូចខាងក្រោម ៖

## I.លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-បានប្រជុំពិភាក្សាការងារជាមួយថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន ប្រជុំថ្ងៃថវិកាឆ្នាំ២០១៤ របស់ព្រឹទ្ធសភាជាមួយតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុទាំងក្របខ័ណ្ឌបច្ចេកទេស និងនយោបាយ ចូលរួមក្នុងពិធីចុះហត្ថលេខាជាមួយអង្គការ Koica និង SSU អំពីកិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍ ប្រជុំគណៈកម្មការពិនិត្យ និងវាយតម្លៃលក្ខណៈសម្បត្តិអ្នករាជការ និងមន្ត្រី១៩រូប ដែលបានថ្លឹងកាត់ការសាកល្បងដឹកនាំការងារ អនុប្រធាននាយកដ្ឋាន ប្រជុំរៀបចំសមាសភាព បែបបទ និងឯកសារសម្រាប់ការចូលរួមមហាសន្និបាត AIPA និងចូលរួមក្នុងពិធីជំនួបសវនាការរបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា ជួបពិភាក្សាការងារជាមួយភ្ញៀវជាតិ អន្តរជាតិ ( ចិន សហរដ្ឋអាមេរិក នូវែលហ្សេឡង់ ) ព្រមទាំងបានពិនិត្យសម្រេចលើឯកសារផ្សេងៗ ចំនួន២៨០ច្បាប់ ។

### ១.សេវាទទួលខុសត្រូវមុខងារតំណាង៖

-រៀបចំបែបបទ និងអមដំណើរថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ចុះទៅតាមណ្ដាខេត្ត រាជធានីទូទាំងប្រទេស ចំនួន១៨៣លើក ដើម្បីសំណេះសំណាល សាកសួរសុខទុក្ខសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ប្រជាពលរដ្ឋ ព្យាបាលជំងឺ ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានា

តាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ស្វែងយល់អំពីស្ថានភាពសិទ្ធិមនុស្ស ការអនុវត្តច្បាប់កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងពិធីផ្លូវការ និងពិធីផ្សេងៗសរុបចំនួន១៨លើក ។

-ទទួលពាក្យបណ្តឹង ចំនួន០៣ករណី និងបានធ្វើលិខិតអន្តរាគមន៍ជូនទៅស្ថាប័នមានសមត្ថកិច្ចដោះស្រាយ ។

**២.ការងារអន្តរជាតិ៖**

-ទទួលគណៈប្រតិភូអគ្គទេសាភិបាល នៃប្រទេសនូវែលហ្សេឡង់ ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក ឯកអគ្គរដ្ឋទូតចិន និងគណៈប្រតិភូចិន ដឹកនាំដោយ Luo Zhaohui ទទួលបន្ទុកកិច្ចសហប្រតិបត្តិការអាស៊ាន-ចិន និងសមុទ្រចិនខាងត្បូង ។

-ជួបពិភាក្សាការងារជាមួយមន្ត្រីស្ថានទូតជប៉ុន និងអ្នកឯកទេសចិន។

-បន្តបែបបទសម្រាប់គណៈប្រតិភូព្រឹទ្ធសភា ទស្សនកិច្ចសិក្សានៅបារាំង និងស្វីស ចូលរួមកិច្ចប្រជុំ ASGFនៅបារាំង មន្ត្រីទស្សនកិច្ចសិក្សានៅថៃ និងឡាវ PICទស្សនកិច្ចសិក្សានៅទីម័រខាងកើត ស៊ុយអែត ស្វីស និងបារាំង ។

-មន្ត្រីអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន៤នាក់ទស្សនកិច្ចសិក្សានៅចិន លើការងារព័ត៌មានវិទ្យា ១រូបចូលរួមកិច្ចប្រជុំ IFLA នៅប្រទេសសឹង្ហបុរី ។

-ការប្រជុំរៀបចំសមាសភាព បែបបទ និងឯកសារសម្រាប់ការចូលរួមមហាសន្និបាត AIPA ខែកញ្ញា នៅប្រទេសប្រុយណេ ។

-ចាត់ចែងការអញ្ជើញក្រុមអ្នកបច្ចេកទេស ICTវៀតណាមមកកម្ពុជា ក្នុងខែកញ្ញា ។

-ទំនាក់ទំនងជាមួយដៃគូអន្តរជាតិនានា ( India, Brunei, Philippine ឥណ្ឌូនេស៊ី ម៉ាឡេស៊ី វៀតណាម ថៃ រុស្ស៊ី អាល្លឺម៉ង់ អូស្ត្រាលី ស្ថានកុងស៊ុលបែលហ្ស៊ិក ស្ថានកុងស៊ុលន័រវែស ) ដើម្បីសុំអាហារូបករណ៍ និងទស្សនកិច្ចសិក្សា ។

**៣.ទំនាក់ទំនងសាធារណៈ៖**

-ទំនាក់ទំនងជាមួយស្ថានីយ៍ទូរទស្សន៍ជាតិ និងទូរទស្សន៍អាស៊ីអាគ្នេយ៍ ដើម្បីផ្សព្វផ្សាយសមិទ្ធផលនានារបស់ព្រឹទ្ធសភា និងសាកលវិទ្យាល័យ CUS, CMTC, CDC, AEU, ECCC, CWF, NiDA, Hong kong Center ដើម្បីសុំអាហារូបករណ៍ និងទស្សនកិច្ចសិក្សា ។

-ទំនាក់ទំនងជាមួយក្រសួងមហាផ្ទៃ ក្រសួងប្រៃសណីយ៍ ទូរគមនាគមន៍ ក្រសួងព័ត៌មាន

ដើម្បីសម្របសម្រួលការផ្ដល់ជូនសមាជិកព្រឹទ្ធសភា ។

-បានទទួលមន្ត្រីរាជការ សិស្ស និស្សិត សាធារណៈជន ចូលអានសៀវភៅ ចំនួ ន៤២៧នាក់ ។

**៤.ការអភិវឌ្ឍន៍ធនធានមនុស្ស៖**

-បើកវគ្គបណ្ដុះបណ្ដាលក្នុងប្រទេស ចំនួន០២វគ្គស្ដីពីការប្រមូលទិន្នន័យតាមវិស័យច្បាប់ និងវគ្គស្ដីពីការវិភាគច្បាប់ ។

-អាហារូបករណ៍ថ្នាក់បរិញ្ញាបត្រ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ចំនួន៤៧នាក់ នៅតាមសាកលវិទ្យាល័យក្នុងប្រទេស

\+ ការបណ្ដុះបណ្ដាលធនធានមនុស្សក្រៅប្រទេស

-មន្ត្រីចំនួន០៣រូប ចូលរួមវគ្គបណ្ដុះបណ្ដាល ស្ដីពីកិច្ចការស្រាវជ្រាវ និងការផ្ដល់សេវា នៅប្រទេសរុស្ស៊ី និងវគ្គស្ដីពីការគ្រប់គ្រងធនធានមនុស្សក្នុងវិស័យសាធារណៈ នៅប្រទេសសិង្ហបុរី ។

-អាហារូបករណ៍ ថ្នាក់បណ្ឌិត និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ចំនួន១៣នាក់ នៅប្រទេសចិន និងវៀតណាម ។

**៥.ការអភិវឌ្ឍន៍ស្ថាប័ន៖**

-បន្តទំនាក់ទំនងជាមួយអ្នកបច្ចេកទេសចិន និងទីប្រឹក្សាពាណិជ្ជកម្មចិនក្នុងការសាងសង់អគារ ០៣ខ្នង០៣ជាន់ ការបំពាក់ជណ្ដើរយន្ត និងការជម្រុញគម្រោងជំនួយសុំបន្ថែម (សាងសង់អគារបន្ថែម ១ខ្នងទៀត, ប្រព័ន្ធលូទឹក, ផ្លូវថ្នល់, ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន, ការសាងសង់សាលប្រជុំ ព្រឹទ្ធសភាថ្មី)។

**៦.សន្តិសុខ ធនធាន មធ្យោបាយ ទីកន្លែង៖**

-អង្គភាពសន្តិសុខផ្ទៃក្នុងព្រឹទ្ធសភា បានចាត់កងកម្លាំងការពារសន្តិសុខ សណ្ដាប់ធ្នាប់ ក្នុងកិច្ចប្រជុំ និងពិធីផ្សេងៗ ចំនួន០៧លើក ។

-ថតចម្លងឯកសារ ចំនួន១១២សំណើ ចងក្រងឯកសារជាសៀវភៅ ចំនួន២១ក្បាល ដោះស្រាយសំណើថវិកា ចំនួន១២៥សំណើ និងសម្ភារ ចំនួន២៧សំណើ ព្រមទាំងផ្ដល់សេវាដឹកជញ្ជូនចំនួន ៦៤លើក។

-ប្រគល់ម៉ាស៊ីនព្រីនធ័រ, USB Modem, Mouse Computer និងKeyboard ចំនួន១០គ្រឿង និងបិទលេខកូដម៉ាស៊ីនព្រីនធ័រ និង Keyboard ចំនួន០២គ្រឿង ។ បញ្ចូលហ្គាស ជួសជុល ម៉ាស៊ីនត្រជាក់ ទូរស័ព្ទ បន្ទប់ទឹក បណ្ដាញខ្សែកាប រាំងនន ទ្វារ ប្ដូរអំពូល ព្រី កុងតាក់ សោរទ្វារ ចំនួន១២៧គ្រឿង។

-ជួសជុលកុំព្យូទ័រ ត្រួតពិនិត្យ បញ្ចូលកម្មវិធីកំចាត់មេរោគ Update Files Antivirus បញ្ចូលកម្មវិធីខ្មែរ Unicode, Office ចុះតាមដាន Internet និង Network សរុបចំនួន ៥១គ្រឿង និងបាន Upload

ព័ត៌មាន និងឯកសារផ្សេងៗ ចំនួន២៣ប្រធានបទ ។

**II.ទិសដៅការងារខែកញ្ញា ឆ្នាំ២០១៣**

១-ត្រៀមរៀបចំពិធីជំនួបរវាងថ្នាក់ដឹកនាំ ជាមួយគណៈប្រតិភូជាតិ អន្តរជាតិ និងអគ្គទូតនានា។

២-ត្រៀមសម្រួលការជួបសវនាការរវាងគណៈកម្មការ ក្រសួង ស្ថាប័ននានា និងការចុះបេសកកម្មតាមបណ្តាខេត្ត។

៣-ការត្រៀមវេទិកាក្រុមភូមិភាគ និងវេទិកាក្រុមសមាជិកាព្រឹទ្ធសភា។

៤-ត្រៀមរៀបចំបែបបទជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភាបំពេញបេសកកម្មក្រៅប្រទេស (ការត្រៀមចូលរួមមហាសន្និបាតអន្តរសភាអាស៊ាន(AIPA)លើកទី៣៤ ថ្ងៃទី១៧ កញ្ញា ដល់ ថ្ងៃទី២៣ កញ្ញា ឆ្នាំ២០១៣ នៅប្រទេសប្រុយណេ។

៥-រៀបចំបែបបទជូនសមាជិកព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមប្រជុំមហាសន្និបាត IPU (ប្រទេសស្វីស) និងចូលរួមក្នុងការប្រជុំសមាគមអគ្គលេខាធិការនៃសភាប្រើភាសាបារាំង នៅប្រទេសបារាំង ។

៦-ការត្រៀមរៀបចំជូនគណប្រតិភូជាន់ខ្ពស់ព្រឹទ្ធសភា ទស្សនកិច្ចនៅចិន។

៧-ពង្រឹងការគោរពវិន័យរក្សាសន្តិសុខ សណ្តាប់ធ្នាប់ បរិស្ថានការងារ ប្រក្រតីកម្ម និងសុខុដុមកម្មនៅក្នុងស្ថាប័ន។

៨-ការត្រៀមរៀបចំបំពាក់ការប៊ីនភ្លើង ជណ្តើរយន្ត ប្រព័ន្ធអគ្គិសនី លូទឹកសួនច្បារនៅក្នុងបរិវេណការដ្ឋាន៣ខ្នង និងក្នុងបរិវេណព្រឹទ្ធសភា។

៩-បន្តរៀបចំលម្អិតគម្រោងថវិកា ឆ្នាំ២០១៤ ក្រោយពីបានការពារគម្រោងថវិកា ឆ្នាំ២០១៤ ជាស្ថាពរជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងបន្តសិក្សាអំពីការកែសម្រួលរចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋាន។

១០-បន្តការបណ្តុះបណ្តាល និងការរកអាហារូបករណ៍ក្នុង និងក្រៅប្រទេសដល់មន្ត្រី ។

១១-បន្តជម្រុញការដ្ឋានសាងសង់អគារ០៣ខ្នង និងបន្តស្វះស្វែងរកជំនួយ និងកិច្ចសហប្រតិបត្តិការពីដៃគូផ្សេងទៀត។

១២- ការរៀបចំដេញថ្លៃគម្រោងលទ្ធកម្មជំហានទី៣ ។

១៣-ពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការរវាងវិទ្យាស្ថានសភាកម្ពុជា និងសភាកម្ពុជា ព្រមទាំងបន្តបើកទ្វារទៅខាងក្រៅដើម្បីរកជំនួយ និងការគាំទ្របន្ថែម ។

១៤-ការរៀបចំបញ្ជូនគណៈប្រតិភូមន្ត្រីទៅទស្សនកិច្ចសិក្សាដកបទពិសោធន៍ នៅសភាឡាវ និងថៃ។

១៥-ការត្រៀមទទួលគណប្រតិភូព្រឹទ្ធសភាបារាំង និងរុស្ស៊ីមកធ្វើទស្សនកិច្ចនៅកម្ពុជា (ខែវិច្ឆិកា) ។

១៦-បន្តពិចារណាអំពីការរៀបចំ និងដាក់ឲ្យអនុវត្តអង្គភាពថវិកា សម្រាប់៤អង្គភាព ជាជំហានដំបូង។

-បន្តពង្រឹងជំហានអនុវត្តការកែទម្រង់ហិរញ្ញវត្ថុសាធារណៈឲ្យកាន់ស៊ីជម្រៅ និងកែសំរួលរចនាសម្ព័ន្ធនាយកដ្ឋានហិរញ្ញវត្ថុ ។

១៧-ការគិតគូរដល់ដំណើរការប្រព័ន្ធការងារមធ្យោបាយ និងធនធានសម្រាប់គ្រប់អង្គភាព ព្រមទាំងជីវភាព សុខុមាលភាព មន្ត្រីរាជការ តាមរបប៣ របបសន្តិសុខសង្គម របបធានារ៉ាប់រងសុខភាព និងរបបសោធននិវត្តន៍ ។

១៨-ត្រៀមការបោះពុម្ពដំណាច់ឆ្នាំ និងរៀបចំប្រទីប ។

១៩-គ្រប់អគ្គនាយកដ្ឋាន និងនាយកដ្ឋានធ្វើផែនការប្រតិបត្តិ ឆ្នាំ២០១៤ និងធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រ តាមគោលដៅ៤ចំណុច ។

២០-បន្តសិក្សាអំពីនីតិវិធីអនុវត្តបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា និងរៀបចំចងក្រងប្រវត្តិព្រឹទ្ធសភា និងប្រវត្តិអគារក្រហម អគារ៤ខ្នង ជាជំនួយរបស់ចិន និងអគារ២ខ្នង ជាជំនួយរបស់ជប៉ុន។

២១-ការរៀបចំបំពាក់គ្រឿងឥស្សរិយយសដល់មន្ត្រី និងគិតគូរការរៀបចំសមាសភាពគ្រប់គ្រងអង្គភាពបេឡាសោធននិវត្តន៍ និងគណៈកម្មការត្រួតពិនិត្យបេឡាសោធននិវត្តន៍ ព្រមទាំងគណៈកម្មការនារីរបស់អគ្គលេខាធិការដ្ឋាន ។

**III.សេចក្តីសន្និដ្ឋាន**

ក្នុងខែសីហានេះ ទាំងអ្នកនយោបាយ និងប្រជាជនកំពុងតាមដានដោយយកចិត្តទុកដាក់លើស្ថានការណ៍ក្រោយការបោះឆ្នោត ដែលកំពុងមានកំដៅ ។ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាបានខិតខំប្រឹងប្រែងពង្រឹងការគោរពវិន័យ បទបញ្ជាផ្ទៃក្នុង សន្តិសុខ ថែរក្សាបរិស្ថាន ការងារ សុខុដុមកម្មផ្ទៃក្នុង និងប្រក្រតីកម្មការងារ ព្រមទាំងខិតខំបំពេញការងារតាមផែនការ ដែលបានកំណត់ឲ្យមានគុណភាព ប្រសិទ្ធភាព និងប្រសិទ្ធផល លេចធ្លោលទ្ធផលមួយចំនួនក្នុងកិច្ចសហប្រតិបត្តិការអន្តរជាតិ ។៚

ភ្នំពេញ,ថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៣

**អគ្គលេខាធិការស្តីទី**

**ឡោក_ឆាយ**